ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រាក់បំណាច់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល

- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ឱ្យបានសមស្របនូវប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ដោយគិតចាប់តាំងពីខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

**មាត្រា ២.-**

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល ហើយដែលកំពុងបម្រើការងារស៊ីប៉ក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ដូចខាងក្រោម :

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធាននាយកដ្ឋាន ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធានការិយាល័យថ្នាក់កណ្តាល ។

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល ហើយដែលស្ថិតនៅក្នុងកម្មសិក្សាក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ដូចខាងក្រោម :

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៣០០ ០០០ រៀល ( **សាមសិបម៉ឺនរៀល** ) ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៦០ ០០០ រៀល ( **ប្រាំមួយម៉ឺនរៀល** ) ។

**មាត្រា ៣.-**

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ដូចមានចែងក្នុងមាត្រា ២ ត្រូវបានជំនួសដោយប្រាក់បំណាច់មុខងារ នៅពេលដែលមន្ត្រីនោះ ទទួលបានការតែងតាំងក្នុងមុខតំណែង ដែលមានប្រាក់បំណាច់មុខងារខ្ពស់ជាងប្រាក់បំណាច់ឧបត្ថម្ភនេះ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ - កាលប្បវត្តិ